25/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ

លេខៈ 2950 អ.យ.ប

# ដីកាសន្និដ្ឋានស្ថាពរ

យើង [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ២៥៤១ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១៨៤៩ អ.យ.ប ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ ១៧៣២ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ លិខិតជូនដំណឹងបញ្ចប់ការស៊ើបសួរលេខ ៦៤៧ "ឡ" ព្រ.ទ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យលេខ ៦៦៥ "ឡ" ព្រ.ទ ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

ឃើញថា ៖

១-នាមត្រកូល-នាមខ្លួន [redacted] ចន្ទា ហៅ តួ ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅ [redacted] ទីលំនៅមុនពេលឃាត់ខ្លួននៅផ្ទះជួល ភូមិតាង៉ូវ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបរ កម្មករសំណង់ នៅលីវ ឪពុកឈ្មោះ [redacted] "រស់" ម្តាយឈ្មោះ [redacted] "រស់" កម្រិតវប្បធម៌បញ្ចប់ថ្នាក់ទី៤ ជានីតិជន ទោសពីមុនគ្មាន ។ (ក្នុងឃុំ)

២-នាមត្រកូល-នាមខ្លួន [redacted] រិទ្ធី ហៅ [redacted] សុខអូរ ភេទប្រុស អាយុ១៤ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅ [redacted] ទីលំនៅមុនពេលឃាត់ខ្លួននៅផ្ទះជួល ភូមិតាង៉ូវ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបរ រត់តុកការ នៅលីវ ឪពុកឈ្មោះ [redacted] "រស់" ម្តាយឈ្មោះ [redacted] "រស់" កម្រិតវប្បធម៌បញ្ចប់ថ្នាក់ទី៣ ជាអនីតិជន ទោសពីមុនគ្មាន។ (ក្នុងឃុំ)

ត្រូវដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទៈ លួចមានស្ថានទម្ងន់ទោស (ឆក់កាបូប) ប្រព្រឹត្តនៅចំណុចក្រោយស្ថានទូតរុស្ស៊ី ផ្លូវសេបិត ក្រុម៧៨ ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៩ ខែ មេសា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

**ឃើញថាៈ** កាលពីថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង១៦និង៤០នាទី នៅចំណុចក្រោយស្ថានទូតរុស្ស៊ី ផ្លូវសេបិត ក្រុម៧៨ ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ មានករណីលួចមានស្ថានទម្ងន់ទោស (ឆក់កាបូប) បួយបានកើតឡើង ប្រព្រឹត្តដោយជនសង្ស័យឈ្មោះ [redacted] **ចន្ថា ហៅ តួ** ភេទប្រុស អាយុ២៥ឆ្នាំ បានជិះម៉ូតូមួយគ្រឿងម៉ាក ZOOMER-X ពណ៌ខ្មៅលាយទឹកក្រូច ពាក់ស្លាកលេខភ្នំពេញ1GH-៨១០៦ ឌុបឈ្មោះ **យ៉ង់ រិទ្ធី ហៅ យ៉ង់ សុខអូរ** ភេទប្រុស អាយុ១៨ឆ្នាំ លុះពេលជិះមកដល់ចំណុចកើតហេតុខាងលើឈ្មោះ [redacted] ចន្ថា ហៅ តួ បានជិះម៉ូតូទៅអែបស្ត្រីរងគ្រោះជាជនបរទេសម្នាក់ដែលកំពុងដើរកាន់កាបូបនៅនឹងដៃខាងឆ្វេង ភ្លាមនោះជនសង្ស័យឈ្មោះ [redacted] រិទ្ធី ហៅ [redacted] សុខអូរ ក៏បានធ្វើសកម្មភាពឆក់កាបូបរបស់ជនរងគ្រោះ តែមិនបានសម្រេច រួចក៏ត្រូវបានកម្លាំងសមត្ថកិច្ចល្បាតរបស់នគរបាលប៉ុស្តិ៍ទន្លេបាសាក់ដែលកំពុងល្បាតក្បែរនោះបានឃើញក៏ធ្វើការដេញតាមឃាត់ខ្លួនបានជនសង្ស័យទាំង ០២នាក់ រួមទាំងវត្ថុតាងម៉ូតូនាំយកមកកាន់នគរបាលប៉ុស្តិ៍ទន្លេបាសាក់ ដើម្បីចាត់ការតាមនីតិវិធីច្បាប់តែម្តង។

**បានឃើញៈ**

-របាយការណ៍សំយោគលេខ **០៣២/២០ រ.ប.ក** ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ របស់អធិការដ្ឋាននគរបាលខណ្ឌចំការមន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

-ចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] **ចន្ថា ហៅ តួ** ភេទប្រុស អាយុ២៥ឆ្នាំ ដែលបានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ តំណាងអយ្យការ និងចៅក្រមស៊ើបសួរប្រហាក់ប្រហែលគ្នាថាៈកាលពីថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០២០ វេលាម៉ោង១៦និង៤០នាទី ខ្លួន និងឈ្មោះ [redacted] **រិទ្ធី ហៅ** [redacted] **សុខអូរ** ភេទប្រុស អាយុ១៨ឆ្នាំ ពិតជាបានធ្វើសកម្មភាពឆក់កាបូបពីស្ត្រីម្នាក់ជាជនជាតិបរទេស ប្រព្រឹត្តនៅចំណុច ក្រោយស្ថានទូតរុស្ស៊ី ផ្លូវសេបិត ក្រុម៧៨ ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ដោយខ្លួនបានជិះម៉ូតូទៅអែបក្បែរស្ត្រីជនជាតិបរទេសនោះ ហើយឈ្មោះ [redacted] **រិទ្ធី ហៅ** [redacted] **សុខអូរ** ជាអ្នកធ្វើសកម្មភាពឆក់កាបូបពីស្ត្រីជនជាតិបរទេស ប៉ុន្តែមិនបានសម្រេច រួចក៏ត្រូវបានកម្លាំងសមត្ថកិច្ចល្បាតរបស់នគរបាលប៉ុស្តិ៍ទន្លេបាសាក់ដែលកំពុងល្បាតក្បែរនោះបានឃើញ ក៏ធ្វើការដេញតាមឃាត់ខ្លួន រួមទាំងវត្ថុតាងម៉ូតូនាំយកមកកាន់នគរបាលប៉ុស្តិ៍ទន្លេបាសាក់ ដើម្បីចាត់ការតាមនីតិវិធីច្បាប់តែម្តង។

-ចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] **រិទ្ធី ហៅ** [redacted] សុខអូរ ភេទប្រុស អាយុ១៨ឆ្នាំ ដែលបានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ តំណាងអយ្យការ និងចៅក្រមស៊ើបសួរប្រហាក់ប្រហែលគ្នាថាៈ កាលពីថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០២០ ខ្លួនបានដើរចេញពីផ្ទះ ក៏បានជួបនឹងមិត្តភក្តិរបស់ខ្លួនឈ្មោះ [redacted] ចន្ថា ហៅ តួ ភេទប្រុស អាយុ២៥ឆ្នាំ ពេលនោះឈ្មោះ [redacted] ចន្ថា ហៅ តួ ក៏បានបបួលខ្លួន

SR

ជិះម៉ូតូដើរលេងនៅមុំកោះពេជ្រ ដោយឈ្មោះ [redacted] ចន្ថា ហៅ តួ ជាអ្នកបើកម៉ូតូម៉ាក ZOOMER-X ពណ៌ខ្មៅលាយទឹកក្រូច ពាក់ស្លាកលេខភ្នំពេញ១GH-៨១០៦ ឌុបខ្លួន លុះពេលជិះទៅដល់ចំណុច ក្រោយស្ពានទូតរុស្ស៊ី ផ្លូវសបិត ក្រុម៧៨ ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ឈ្មោះ [redacted] ចន្ថា ហៅ តួ និងខ្លួនបានឃើញស្ត្រីជនជាតិបរទេសម្នាក់ កំពុងដើរកាន់កាបូបយួរដៃនៅទីងខាងឆ្វេងក្ឋាមនោះខ្លួនក៏បានឲ្យឈ្មោះ [redacted] ចន្ថា ហៅ តួ ជិះម៉ូតូត្រឡប់ក្រោយ រួចឈ្មោះ [redacted] ចន្ថា ក៏បានជិះម៉ូតូអែបស្ត្រីជនជាតិបរទេសនោះ ហើយខ្លួនក៏បានធ្វើសកម្មភាពឆក់កាបូបពីស្ត្រីជនជាតិបរទេសនោះ តែមិនបានសម្រេច រួចពួកខ្លួនក៏ជិះម៉ូតូគេចខ្លួន ក៏ត្រូវបានកម្លាំងសមត្ថកិច្ចល្បាតរបស់នគរបាលប៉ុស្តិ៍ទន្លេបាសាក់ដែលកំពុងល្បាតក្បែរនោះបានឃើញ ក៏ធ្វើការដេញតាមឃាត់ខ្លួន រួមទាំងវត្ថុតាងម៉ូតូនាំយកមកកាន់នគរបាលប៉ុស្តិ៍ទន្លេបាសាក់ ដើម្បីចាត់ការតាមនីតិវិធីច្បាប់តែម្តង។

- ពាក្យស្នើសុំម៉ូតូ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០២០ របស់ឈ្មោះ [redacted] សុខឡាង ភេទស្រី អាយុ ៣៥ឆ្នាំ។

-ដីកាបង្គាប់ឱ្យប្រគល់វត្ថុចាប់យកទៅម្ចាស់ដើមវិញលេខ ២០៦ អ.យ.ច ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ២០២០ របស់អយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ។

-ដីកាបង្គាប់ឱ្យឃុំខ្លួនឈ្មោះ [redacted] រិទ្ធី ហៅ [redacted] សុខអូរ ភេទប្រុស អាយុ១៤ឆ្នាំ លេខ ៤៣៤២ "ឡ" ជ.ឃ.ជ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-ដីកាបង្គាប់ឱ្យឃុំខ្លួនឈ្មោះ [redacted] ចន្ថា ហៅ តួ ភេទប្រុស អាយុ២៥ឆ្នាំ លេខ ៤៣៤៣ "ឡ" ជ.ឃ.ជ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-ឯកសារពាក់ព័ន្ធនានាក្នុងសំណុំរឿង ។

**<u>យល់ឃើញថា</u>**

-តាមរបាយការណ៍សំយោគរបស់មន្ត្រីនគរបាលយុត្តិធម៌ ចម្លើយរបស់ជនរងគ្រោះ, ចម្លើយរបស់ជនត្រូវចោទ ព្រមទាំងភស្តុតាងនានាមានភាពស៊ីសង្វាក់គ្នា ដែលអាចបញ្ជាក់បានថា៖ ជនត្រូវចោទឈ្មោះ [redacted] ចន្ថា ហៅ តួ ភេទប្រុស អាយុ២៥ឆ្នាំ, ឈ្មោះ [redacted] រិទ្ធី ហៅ [redacted] សុខអូរ ភេទប្រុស អាយុ១៤ឆ្នាំ ពិតជាមានចេតនាដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិរបស់អ្នកដទៃ យកមកធ្វើជារបស់ខ្លួន កាលពីថ្ងៃទី ០៥ ខែ មេសា ឆ្នាំ២០២០ ប្រព្រឹត្តនៅចំណុចក្រោយស្ពានទូតរុស្ស៊ី ផ្លូវសបិត ក្រុម៧៨ ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រាកដមែន ។

-ជនត្រូវចោទឈ្មោះ [redacted] ចន្ថា ហៅ តួ ភេទប្រុស អាយុ២៥ឆ្នាំ និងឈ្មោះ [redacted] រិទ្ធី ហៅ [redacted] សុខអូរ ភេទប្រុស អាយុ១៤ឆ្នាំ មានចេតនាទុច្ចរិតក្នុងការយកទ្រព្យសម្បត្តិរបស់អ្នកដទៃមកធ្វើជាប្រយោជន៍របស់ខ្លួន។

-អំពើប្រព្រឹត្តរបស់ជនត្រូវចោទឈ្មោះ [redacted] ចន្ថា ហៅ តួ ភេទប្រុស អាយុ២៥ឆ្នាំ, ឈ្មោះ [redacted] រិទ្ធី ហៅ [redacted] សុខអូរ ភេទប្រុស អាយុ១៤ឆ្នាំ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

SR

-ក្នុងពេលប្រព្រឹត្តបទល្មើសជនត្រូវចោទឈ្មោះ [redacted] រិទ្ធី ហៅ [redacted] សុខអួរ ភេទប្រុស អាយុ១៤ឆ្នាំ ជាអនីតិជន ពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការយល់ដឹងនូវអំពើដែលខ្លួនបានប្រព្រឹត្ត និងត្រូវទទួលខុសត្រូវតាមកំណត់ច្បាប់ ចំណែកឯឈ្មោះ [redacted] ចន្ថា ហៅ តួ ភេទប្រុស អាយុ២៥ឆ្នាំ ជានីតិជន ដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការយល់ដឹងនូវអំពើដែលខ្លួនបានប្រព្រឹត្ត និងត្រូវទទួលខុសត្រូវតាមត្រូវតាមកំណត់ច្បាប់ ។

-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទឈ្មោះ [redacted] ចន្ថា ហៅ តួ ភេទប្រុស អាយុ២៥ឆ្នាំ និងឈ្មោះ [redacted] រិទ្ធី ហៅ [redacted] សុខអួរ ភេទប្រុស អាយុ១៤ឆ្នាំ ពីបទ **លួចមានស្ថានទម្ងន់ទោស (ឆក់កាបូប)** ប្រព្រឹត្តនៅចំណុចក្រោយស្ពានទូតរុស្ស៊ី ផ្លូវសបិត ក្រុម៧៨ ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៥ ខែ មេសា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

## ហេតុដូច្នេះ

**០១.ចោទប្រកាន់៖**

-ឈ្មោះ [redacted] ចន្ថា ហៅ តួ ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ (ក្នុងឃុំ)

-ឈ្មោះ [redacted] រិទ្ធី ហៅ [redacted] សុខអួរ ភេទប្រុស អាយុ១៤ឆ្នាំ ជនជាតិខ្មែរ (ក្នុងឃុំ)

ពីបទ៖ **លួចមានស្ថានទម្ងន់ទោស (ឆក់កាបូប)** ប្រព្រឹត្តនៅចំណុចក្រោយស្ពានទូតរុស្ស៊ី ផ្លូវសបិត ក្រុម៧៨ ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៥ ខែ មេសា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

**០២. បញ្ជូនជនជាប់ចោទ៖**

-ឈ្មោះ [redacted] ចន្ថា ហៅ តួ ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ (ក្នុងឃុំ)

-ឈ្មោះ [redacted] រិទ្ធី ហៅ យ៉ង់ សុខអួរ ភេទប្រុស អាយុ១៤ឆ្នាំ ជនជាតិខ្មែរ (ក្នុងឃុំ)

ព្រមទាំងវត្ថុតាងនានាជាប់ពាក់ព័ន្ធក្នុងសំណុំរឿងទៅចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ សម្រេចបញ្ជូនជនត្រូវចោទនេះទៅជំនុំជម្រះតាមច្បាប់ ។

ថ្ងៃ ...ព្រហស្បតិ៍ ១៤កើត... ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ...០៤.... ខែ មិថុនា ឆ្នាំ ២០២០

**ជ.ព្រះរាជអាជ្ញា**

[redacted]

ព្រះរាជអាជ្ញារង